ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# ដំណាំម្ទេសហិល



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ៖

ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៥



**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៨៥

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / **Department of Agricultural Extension**

**គេហទំព័រ** : **http://www.maff.gov.kh** / អ៊ីម៉ែល : **info@maff.gov.kh**

# សៀវភៅ

# ស្ដីពី

# ដំណាំម្ទិសហិល

## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

បោះពុម្ពលើកទី១ ចំនួន ២០០០ច្បាប់

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីដំណាំម្ទេសហិល

I. ទីប្រឹក្សាផ្តល់យោបល់:

១. បណ្ឌិត **ម៉ាក់ សឿន** អគ្គនាយកដ្ឋានកសិកម្ម

២. បណ្ឌិត **ម៉ៅ មីនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ប៉ែន ឧត្តម** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **គីម ដារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

២. លោកស្រី **កែវ ចាន់ដារី** ក្រុមហ៊ុន East-West Seed International Ltd.,

III. ក្រុមការងារស្រាវជ្រាវ:

១. លោក **រស់ គំនិត** ក្រុមហ៊ុន East-West Seed International Ltd.,

២. លោក **ចាប ចិន្តា** ក្រុមហ៊ុន East-West Seed International Ltd.,

៣. លោក **ភុំ ដារ៉ា** ក្រុមហ៊ុន East-West Seed International Ltd.,

៤. កញ្ញា **លេន ធីតា** ក្រុមហ៊ុន East-West Seed International Ltd.,

៥. លោក **ទឹម សុបាន** ក្រុមហ៊ុន East-West Seed International Ltd.,

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **ពេជ សុខន្តារា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

២. លោក **ហុង ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. កញ្ញា **ជុំ ខណ្ឌារិទ្ធ** នាយកដ្ឋានសារព្យកម្ម និងដំណាំរួមផ្សំ

៤. លោក **ណុប សំណាង** នាយកដ្ឋានសារព្យកម្ម និងដំណាំរួមផ្សំ



## មាតិកា

ទំព័រ


១. ការរៀបចំដី..........................................០១

២. ការរានបណ្ដុះកូនម្ទេស...............................០៨

៣. ការបណ្ដុះគ្រាប់.......................................១១

៤ . ការដាំកូនម្ទេស.....................................១៣

៥. ការថែទាំ..............................................១៦

៦. ជំងឺ និងសត្វល្អិតចង្រៃ ...............................២១

៧. ការប្រមូលផល.........................................២៥

# ដំណាំម្ទេសហិល

## ១.ការរៀបចំដី

- ភ្ជួរដីជម្រៅ ២តឹក ទៅ ៣តឹក (២០សង្ទីម៉ែត្រ ទៅ ៣០សង្ទីម៉ែត្រ)
- ភ្ជួររាស់ឱ្យបានម៉ដ្ឋល្អ ហើយហាលដីពី១០ ទៅ ១៥ថ្ងៃមុនពេលដាំ



**ផលប្រយោជន៍ នៃការភ្ជួររាស់ដី៖**

- កម្ចាត់សត្វល្អិតចង្រៃ និងជំងឺ
- ដីធូ មានខ្យល់ចេញចូល បានល្អ ឫសដំណាំដុះលូតលាស់ខ្លាំង
- អាចរក្សាសំណើមដីបានល្អ

- **ការលើករងដាំ៖**

កសិករត្រូវចាប់ផ្តើមលើករងដាំកូនម្ទេសឱ្យបានរួចរាល់ ពី៥ ទៅ ៧ថ្ងៃមុនអាយុកាលកូនម្ទេសត្រូវយកទៅដាំ។

របៀបធ្វើរងដាំម្ទេសមានដូចខាងក្រោម៖

- ទទឹងរង១ម៉ែត្រ
- បណ្តោយ រងធ្វើតាមលទ្ធភាពតែមិនគួរលើសពី ២៥ម៉ែត្រទេ។ ការលើករងវែងពេកវានាំឱ្យយើងពិបាកចូលស្រោចទឹក ធ្វើស្មៅ ដាក់ជីបាញ់ថ្នាំ និងប្រមូលផល។
- រងនៅរដូវវស្សាត្រូវមានកម្ពស់ពី ៣តឹក - ៥តឹក (៣០សង្ទីម៉ែត្រ - ៥០សង្ទីម៉ែត្រ)
- ចន្លោះគុម្ព ៥០សង្ទីម៉ែត្រ ចន្លោះជួរ ៧៥សង្ទីម៉ែត្រ។




៖ ច្របល់ជីលាមកសត្វពុកផុយ ឬជីកំប៉ុស្ត១-២ គីឡូក្រាមលាយជាមួយជី អិន ប៉េ កា (២០.២០.១៥) ចំនួន១០ក្រាម (១ស្លាបព្រាបាយ) សម្រាប់ដាំម្ទេស១ដើម ឬជី២០.២០.១៥ ចំនួន៨,៥គីឡូក្រាមសម្រាប់ ដី៥០០ម²។ ជៀសវាងដាក់ជីលាមកសត្វមិនទាន់ពុកផុយពីព្រោះវាបង្កឱ្យកូនម្ទេសហិលរលួយ។

## ផលប្រយោជន៍នៃការដាក់ជីទ្រាប់បាត៖



៖ ដាក់ជីលាមកសត្វ ពុកផុយ ឬជីកំប៉ុស្តទ្រាប់បាតជួយឱ្យដីធូ ឫសងាយដុះលូតលាស់

៖ ដាក់ជី អិន ប៉េ កា ទ្រាប់បាតគឺជំរុញកូនម្ទេស ទើបនឹងដាំ អាចដុះលូតលាស់ឫស បានច្រើន និងរឹងមាំ ហើយដើមនឹងស្លឹកដុះបានឆាប់រហ័ស។

❀ ស្រោចទឹកលើរងដាំឱ្យជោគដល់ខាងក្នុងរងមុនគ្របប្លាស្ទីកឬចំបើង



**ផលប្រយោជន៍នៃការស្រោចទឹកមុនគ្របរង៖**

❀ ដីត្រជាក់កូនម្ទេសងាយដុះលូតលាស់

❀ កាត់បន្ថយចំនួនកូនម្ទេសសន្លប់(អន់) ឬងាប់ក្រោយពីដាំហើយ ។

❀ គ្របរងដាំ៖ បន្ទាប់ពីដាក់ជីទ្រាប់បាត និងស្រោចទឹកតាមរងឱ្យជោគហើយ កសិករចាប់ផ្តើមគ្របរងបាន។

មានសម្ភារពីរប្រភេទអាចជ្រើសរើសយកមកគ្របរងដាំដំណាំម្ទេសគឺ៖




## ក. ប្លាស្ទីកគ្របដីនិងរបៀបប្រើ

យើងដំឡើងប្លាស្ទីកតាមរងដាំម្ទេសនីមួយៗដូចវិធីខាងក្រោម៖

❀ ទាញដុំប្លាស្ទីកតាមបណ្តោយរងដោយយកស្រទាប់ពណ៌សដាក់ខាងលើ និងស្រទាប់ពណ៌ខ្មៅដាក់ខាងក្រោម

❀ ខ្ទាស់បន្ទះឬស្សីពីលើប្លាស្ទីកជាប់នឹងដីនៅគល់និងចុងរងដាំបន្លែឱ្យញឹក




- ទាញប្លាស្ទីកតាមបណ្ដោយរង
- យកបន្ទះឫស្សីខ្នាស់តាមគែមរងប្រវែងពី ៣-៤តឹក សម្រាប់ខ្នាស់មួយកន្លែង




- ប្រើខ្នាត់ សម្រាប់វាស់វែងចន្លោះគុម្ព
- ចុងខ្នាត់ចាក់ទម្លុះប្លាស្ទីកសម្រាប់ដៅចោះរណ្ដៅ
- ប្រវែងខ្នាត់ អាស្រ័យតាមប្រភេទដំណាំ។




- ចោះរណ្ដៅតាមខ្នាត់បានដៅទុក
- ប្រើកំប៉ុងក្ដៅ( ដាក់រងើកភ្លើង ) ឬ ឧបករណ៍ផ្សេងៗទៀតសម្រាប់ចោះរណ្ដៅលើប្លាស្ទីក
- កំប៉ុងសម្រាប់ចោះ គួរមានមុខកាត់ ១តឹកកន្លះ។ បើមុខកាត់កំប៉ុងតូច កម្ដៅងាយឆួល ចេញពីខាងក្នុង ប្លាស្ទីក ធ្វើឱ្យស្លោកកូនបន្លែបន្ទាប់ពីដាំហើយ។




- រងម្ទេសបានចោះរណ្ដៅរួច ហើយ ត្រៀមសម្រាប់ដាំកូនម្ទេស

## ប្រការត្រូវចងចាំនៅពេលគ្របប្លាស្ទីក

- មិនត្រូវគ្របប្លាស្ទីកធូរពេកទេ។ ព្រោះវាធ្វើឱ្យមានខ្យល់ក្ដៅចេញចូលក្នុងរងក្រោមប្លាស្ទីក បង្កឱ្យកូនម្ទេសងាប់ ហើយប្លាស្ទីកនឹងងាយរហែក។ តែក៏មិនត្រូវទាញវាឱ្យតឹងខ្លាំងពេកនោះទេ ពីព្រោះវានឹងងាយរហែក។



ការគ្របក្នុងរូបភាពបែបនេះគឺមិនត្រឹមត្រូវទេ



ការគ្របក្នុងរូបភាពបែបនេះទើបជាការត្រឹមត្រូវ

### អត្ថប្រយោជន៍ នៃការគ្របរងដោយប្លាស្ទកគ្របដី

វាមានផលប្រយោជន៍ជាច្រើននៅរដូវវស្សាដូចជា៖

- កាត់បន្ថយជាំទឹកដំណាំ
- កាត់បន្ថយការហូរច្រោះដីរងដំណាំ
- ដីរងមិនហាប់ (ដីនៅធូរ)ធ្វើឱ្យឫសដំណាំងាយចាក់បានស្រួល
- កាត់បន្ថយការបាត់បង់ជី
- កាត់បន្ថយការដុះស្មៅ
- កាត់បន្ថយជម្រកសត្វល្អិតចង្រៃ និងជំងឺ

## ខ. ការគ្រប់គ្រង និងរបៀបប្រើប្រាស់ចំបើង



១

គ្របចំបើងកម្រាស់ពី០,៦តឹក ទៅ១តឹក (៦សង្ទីម៉ែត្រ ទៅ ១០សង្ទីម៉ែត្រ)



២

រងគ្របចំបើងត្រៀមដាំកូនម្ទេស

### អត្ថប្រយោជន៍ នៃការប្រើចំបើង

វាផ្តល់ផលប្រយោជន៍ច្រើននៅរដូវប្រាំង៖

- រក្សាសំណើមដីបានយូរ
- កាត់បន្ថយការហូរច្រោះដីរងដំណាំ
- ដីរងមិនហាប់ (ដីនៅធូរ)ធ្វើឱ្យឫសដំណាំងាយដុះបានលឿន
- កាត់បន្ថយការបាត់បង់ជី ការដុះស្មៅ និងជួយឱ្យដីធូរបន្ទាប់ពីចំបើងរលួយ




ចំបើងត្រូវដាក់ឱ្យឃ្លាតឆ្ងាយពីគល់កូនម្ទេសដូចរូបនេះ ជៀសវាងចំបើងបង្កឱ្យដើមកូនម្ទេសរលួយ

## ២. ការធ្វើវានបណ្តុះកូនម្ទេស

ការបណ្តុះកូនម្ទេសមិនបានត្រឹមត្រូវតាមបច្ចេកទេស នោះកសិករនឹងមានការខាតបង់ជាច្រើនដូចជា៖

- ខាតបង់គ្រាប់ដោយសារគ្រាប់មិនដុះ និងមានកូនម្ទេសងាប់ច្រើន
- កសិករត្រូវការពេលវេលា និងចំណាយជីច្រើនសម្រាប់បំប៉ន
- កសិករមិនអាចប្រមូលផល ឬប្រមូលផលបានតិច ដោយសារកូនម្ទេសក្រិន ឬមានជំងឺ
- ម្ទេសមានសុខភាពខ្សោយ ងាយរងការបំផ្លាញពីសត្វល្អិតចង្រៃ និងជំងឺ

ដើម្បីទទួលបានទិន្នផលបានខ្ពស់ កសិករគួរតែផលិតកូនម្ទេស ឱ្យបានថ្លោសៗល្អ និងមិនមានជំងឺជាប់មកជាមួយនៅពេលយកវាមកដាំ។ ដើម្បីបានកូនម្ទេសថ្លោសល្អ កសិករគួរអនុវត្តតាមបច្ចេកទេស ដូចខាងក្រោម៖

- ត្រូវសង់រោងបណ្តុះ នៅកន្លែងណា ដែលមានពន្លឺគ្រប់គ្រាន់ និងមិននៅក្បែរដើមឈើ

- នៅរដូវវស្សាដំបូលត្រូវមានពណ៌សដើម្បីឱ្យពន្លឺថ្ងៃចាំងចូលកូនម្ទេសគ្រប់គ្រាន់។ ជៀសវាងធ្វើដំបូលរានកូនម្ទេសហិលពីស្លឹកដូង តង់ពណ៌ខៀវ ឬពីសម្ភារផ្សេងទៀតដែលមិនអាចឱ្យពន្លឺចូលរួច ពីព្រោះវានឹងធ្វើគ្រាប់ម្ទេសដុះឃើតដើមកូនម្ទេស ទន់ ឬងាយរលួយគល់ ។
- ធ្វើដំបូលរងពីសំណាញ់កាត់ពន្លឺនៅរដូវប្រាំង
- រងមានកម្ពស់ ពី២ ម៉ែត្រ ទៅ ២ម៉ែត្រកន្លះពីដី
- រានបណ្តុះគួរមានកម្ពស់កន្លះម៉ែត្រពីដី
- រានបណ្តុះអាចធ្វើពីឬស្សី ក្តារ និងសម្ភារដទៃទៀត ដែលអាចរកបាន។ មិនត្រូវក្រាលដីបាវក្រចៅ ឬសម្ភារណា ដែលជក់ទឹក ពីលើរានសម្រាប់ដាក់កន្ទោង ឬថាសបណ្តុះនោះទេ ពីព្រោះវាអាចនាំមកជាមួយនូវជំងឺ និងធ្វើឱ្យឬសចាក់ចុះហួសកន្ទោងបណ្តុះ។

រានបណ្តុះសម្រាប់រដូវវស្សា



រានបណ្តុះសម្រាប់រដូវប្រាំង




## ផលប្រយោជន៍ នៃការធ្វើរានបណ្តុះ៖

- ការពារកូនដំណាំ បានពីការឆ្លងជំងឺ និងសត្វល្អិតចង្រៃ
- បញ្ចៀសការរលួយកូនម្ទេសនូវរដូវវស្សានិងក្រិននៅរដូវប្រាំង

❀ កាត់បន្ថយការឆ្លងជំងឺហូរតាមដីមកកូនម្ទេស

## ៣. ការបណ្តុះគ្រាប់

❀ ការរៀបចំដីបណ្តុះ

យកដីមានជីជាតិ១ ភាគ លាយជាមួយជីលាមកគោស្ងួត ឬ ជីកំប៉ុស្តិ៍ ២ ភាគ និងផេះអង្កាម ពី២ ទៅ ៣ភាគ អាស្រ័យតាមប្រភេទដី( ផេះអង្កាមត្រូវត្រាំទឹករយៈពេលពី២ទៅ ៣យប់ ) ។ យកល្បាយដែលបានលាយច្របល់ហើយទៅលីង ឬចំហុយរហូតក្តៅសព្វ តែត្រូវឱ្យដីនោះនៅសើមតិចៗទើបមិនខូចគុណភាពដី។




**ផលប្រយោជន៍ នៃការរៀបចំដីសម្រាប់បណ្តុះ៖**

- គ្រាប់ងាយដុះឬសហើយដុះលូតលាស់ល្អ
- កូនម្ទេសមានជីគ្រប់គ្រាន់សម្រាប់ចិញ្ចឹមដើម ស្លឹក ឫសរបស់វា
- សម្លាប់មេរោគ( ជំងឺ ) ដែលបង្កឱ្យកូនម្ទេសរលួយ
- សម្លាប់គ្រាប់ស្មៅចង្រៃនៅក្នុងដីបណ្តុះដែលដុះដណ្តើមយកជីពីកូនម្ទេស

- សម្លាប់ពងសត្វល្អិត និងសត្វល្អិតចង្រៃក្នុងដីដែលស៊ីបំផ្លាញគ្រាប់បម្ទេស

## ការបណ្ដុះគ្រាប់

- យកដីបណ្ដុះបានលីង ឬចំហុយ ហើយដាក់ក្នុងកន្ទោង ឬថាសបណ្ដុះ។







- ស្រោចទឹកដីបណ្ដុះ ឱ្យជោគមុនដាក់គ្រាប់



- ដាក់គ្រាប់ម្ទេស១គ្រាប់ក្នុង១ប្រហោះថាសបណ្ដុះឬ ក្នុង ១កន្ទោង រួចយកដីរោយលុបពីលើគ្រាប់នោះ។ មិនត្រូវកប់គ្រាប់ម្ទេសជ្រៅនោះទេ វាអាចធ្វើឱ្យគ្រាប់រលួយ ឬដុះយឺត។

- របៀបថែទាំកូនម្ទេស

- ស្រោចទឹកកូនម្ទេសឱ្យជោគនៅពេលព្រឹក និងពេលថ្ងៃ។ មិនគួរស្រោចទឹកនៅពេលល្ងាចទេ ពីព្រោះទឹកស្រោចនៅពេលល្ងាច( ក្រោយម៉ោង៥ល្ងាច ) វានឹងងាយធ្វើឱ្យគ្រាប់សើមជ្រុល ឬសកូនម្ទេសសើមពេកបង្កឱ្យកូនម្ទេសរលួយបានយ៉ាងឆាប់រហ័ស។
- កូនម្ទេសអាយុបានបាន១០ទៅ១៥ថ្ងៃ ត្រូវស្រោចជី ដែលមានធាតុផូស្វ័រច្រើន( ជីប៉េ ) មានដូចជាជី ១៨-៤៦-០ ឬ ១៦-២០-០ ដើម្បីជួយកូនម្ទេសមានឫសច្រើននិងរឹងមាំ ។ យកជីណាមួយខាងលើ ចំនួន១ស្លាបព្រាបាយស្មើលាយទឹកចំនួន១០លីត្ររួចកូរវាឱ្យរលាយទើបស្រោចកូនម្ទេស។ យើងត្រូវស្រោចទឹកធម្មតាដើម្បីលាងកូនម្ទេសបន្ទាប់ពីស្រោចជីហើយ។

## ៤ . ការដាំកូនម្ទេស

- កូនម្ទេសមានអាយុ២៥ថ្ងៃ (មានស្លឹកបី) យើងយកវាទៅដាំបាន។ បើយើងដាំកូនម្ទេស មានអាយុចាស់ជាងនេះ យើងនឹងខាតផលប្រយោជន៍ដូចជា៖

- កូនម្ទេសខ្សោយ( ស្គមៗ )
- មានខ្នែងបែកតិច
- កាត់បន្ថយទិន្នផលជ្រុល ឬសកូនម្ទេសសើមពេក បង្កឱ្យរលួយបានយ៉ាងឆាប់រហ័ស

- ត្រូវពង្រឹងកូនម្ទេស ចំនួន៥ទៅ៧ថ្ងៃមុនដកយកដាំ (ត្រូវដាក់កូនម្ទេសឱ្យត្រូវពន្លឺថ្ងៃ តែជៀសវាងដាក់ពេលថ្ងៃត្រង់)និងបន្ថយស្រោចទឹករហូតដល់ពេលយកកូនទៅដាំ។



ការពង្រឹងកូនម្ទេសហិលបានត្រឹមត្រូវនិងទទួលបានអត្ថប្រយោជន៍ដូចជា៖

- ដើមកូនម្ទេសរឹងមាំល្អ
- កូនម្ទេសមិនចាញ់អាកាសធាតុខាងក្រៅ
- មានដាច់ឫសតិចតួចបំផុតនៅពេលដកកូនដាំ
- កូនម្ទេសមិនសន្លប់(អន់)ឬមានងាប់តិចតួចបំផុតបន្ទាប់ពីដាំហើយ។

- ស្រោចទឹកកូនម្ទេស១-២ម៉ោង មុនពេលដកដាំទើបដីបណ្ដុះមិនបែក។ ត្រូវដាំកូនម្ទេសពេលរសៀល
- ស្រោច និងបញ្ចូលទឹកឱ្យជោគរងដាំនៅពេលព្រឹក។ បើយើងបានស្រោចទឹកឱ្យសព្វដីពេលព្រឹកបែបនេះនឹងធ្វើឱ្យដីក្នុងរងមានភាពសើមបានយូរ ជួយកាត់បន្ថយការភាយកម្ដៅពីរងគ្របប្លាស្ទិក ហើយកូនម្ទេសងាប់មានចំនួនតិចតួចបំផុតបន្ទាប់ពីដាំរួច ជាពិសេសយើងងាយស្រួលដើរទៅតាមចន្លោះរងក្នុងពេល ដាំកូនម្ទេសហិល។







### របៀបដកកូនម្ទេសហិលចេញពីថាសបណ្តុះ

- យកម្រាមដៃច្របាច់បាតថាស ឬរុញដីក្នុងរន្ធនៅបាតថាសទៅលើ
- ដៃម្ខាងទៀតទាញគល់កូនម្ទេសឡើង

- ដាំកូនម្ទេសត្រឹមដីកំណើតនោះជួយឱ្យកូនដុះបានល្អ
- ប្រសិនបើកប់កូនវា ក្នុងរណ្តៅជ្រៅលិចបាត់ដីកំណើតនោះ កូនម្ទេសលូតលាស់យឺត ឬងាយងាប់។

ដាំត្រឹមដីកំណើតតាមបែបនេះ

## ៥. ការថែទាំ

### ៥. ១. ការប្រើប្រាស់ជី

ការជ្រើសរើសប្រភេទជីសម្រាប់ដាក់ម្ទេស និងត្រូវតាមពេលវេលានៃដំណាក់កាលលូតលាស់ដំណាំ ព្រមទាំងដាក់ជីតាមបរិមាណដែលដំណាំត្រូវការនោះយើងពិតជាចំណាយថវិការទិញជីអស់តិច ហើយដំណាំផ្តល់ទិន្នផលបានខ្ពស់។

### ក. ប្រភេទជី និងពេលវេលាប្រើប្រាស់ជី

ពូជម្ទេសបង្កាត់ (អ៊ីប្រ៊ីដ)ត្រូវដាក់ជីប៉ប៉នឱ្យបានទៀងទាត់ ទើបវាអាចផ្តល់ផ្លែ ផ្កាបានច្រើន។ ជាការប្រសើរគួរដាក់ជីប៉ប៉នរៀងរាល់៧ ទៅ ១៥ថ្ងៃម្តងបន្ទាប់ពីដាំកូនម្ទេស តែវាអាស្រ័យទៅតាមរដូវកាលដាំដុះប្រភេទដី និងស្ថានភាពលូតលាស់ម្ទេសផងដែរ។ ឧទាហរណ៍ ប្រភេទដីខ្សាច់ត្រូវដាក់ជីឱ្យបានញឹកញាប់ តែដាក់បរិមាណតិច ដោយសារប្រភេទដីនេះងាយហូរច្រោះជី ទឹកលឿន ដូច្នេះបើយើងដាក់ជីច្រើននោះវានឹងបាត់បង់ដោយសារហូរតាមទឹក ហើយដំណាំស្រូបយកបានតិចតួច ។

ជៀសវាងជ្រើសរើសជីដែលខូចគុណភាព (មានកកជាដុំៗឬមានភាពសើម) និងដាក់ជីប៉ប៉នបន្ថែមពេលថ្ងៃក្តៅ ព្រោះវានឹងអាចបង្កឱ្យដំណាំងាប់បាន។



## បរិមាណ និងពេលវេលាដាក់ជីសម្រាប់ដំណាំម្ទេសហិលផ្ទៃដី៨០០ ម៉ែត្រការ៉េ

| ចំនួនថ្ងៃ បន្ទាប់ពីដាំ | ប្រភេទជី | ចំនួនជី/ដើម | ចំនួនដើម សរុប | ជីសរុប (គ.ក្រ) | ទីតាំងដាក់ជី |
|---|---|---|---|---|---|
| ទ្រាប់បាត | ជី ២០-២០-១៥ | ១០ក្រាម | ៨៥៨ | ៨,៥៨ | ពង្រាយលើរង |
| ១០ ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១០សង្ទីម៉ែត្រពីគល់ |
| | ជី៤៦-០-០ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១០សង្ទីម៉ែត្រពីគល់ |
| ២០ ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១០សង្ទីម៉ែត្រពីគល់ |
| | ជី៤៦-០-០ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១០សង្ទីម៉ែត្រពីគល់ |
| ៣០ ថ្ងៃ | ជី០-០-៦០ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១០សង្ទីម៉ែត្រពីគល់ |
| | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១០សង្ទីម៉ែត្រពីគល់ |
| ៤០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១៥សង្ទីម៉ែត្រពីគល់ |
| | ជី០-០-៦០ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១៥សង្ទីម៉ែត្រពីគល់ |
| ៥០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១៥សង្ទីម៉ែត្រពីគល់ |
| | ជី០-០-៦០ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ១៥សង្ទីម៉ែត្រពីគល់ |
| ៦០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |
| ៧០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |
| | ជី០-០-៦០ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |
| ៨០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |
| | ជី០-០-៦០ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |
| ៩០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |
| ១០០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |
| ១១០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |
| ១២០ថ្ងៃ | ជី ២០-២០-១៥ | ២,៥ ក្រាម | ៨៥៨ | ២,១៤៥ | ២៥សង្ទីម៉ែត្រពីគល់ |

គួរឈប់ដាក់ជីរយៈពេល១ខែ មុនបញ្ចប់ការប្រមូលផល។

## ប្រការជៀសវាងនៅពេលដាក់ជី

គ្រប់ប្រភេទជីគីមីគ្រាប់ទាំងអស់ ៖

- មិនត្រូវយកជីដាក់នៅក្បែរគល់ដំណាំទេ ជីទាំងនោះនឹងបង្កឱ្យឆ្លូលក្តៅធ្វើឱ្យដំណាំងាប់បានយ៉ាងងាយ
- មិនត្រូវយកជីដាក់នៅលើដីចោល ។ ការដាក់ជីបែបនេះមានការខាតចិរិកាជាច្រើនពីព្រោះថាដំណាំពុំអាចស្រូបយកវាបានដោយសារបាត់បង់ដោយសារកម្ដៅថ្ងៃ និងខ្យល់ហួត។



ហាមយកជីគីមីប្រភេទគ្រាប់គ្រប់ប្រភេទដាក់ចំដើមម្ទេស

## ខ. របៀបដាក់ជីក្នុងរងគ្របប្លាស្ទិកគ្របដីនិងចំបើង

- យើងត្រូវយកឈើមកបុកជារណ្តៅពីលើរងគ្របចំបើង និងប្លាស្ទិកជម្រៅប្រមាណជា៥ សង្ទីម៉ែត្រ (កន្លះតឹក) នៅសងខាងរណ្តៅ សម្រាប់ដាក់ជីបំប៉ន
- ជម្រៅរណ្តៅដាក់ជីត្រូវតែរាក់ល្មម ទើបឫសដំណាំអាចចាប់យកជីនោះបាន។



រណ្តៅកប់ជីបំប៉ន

## ៥. ២. ការស្រោចទឹក

- នៅចន្លោះពេលពីដាំកូនម្ទេសបាន២សប្តាហ៍ ត្រូវស្រោចទឹករៀងរាល់ថ្ងៃ ដើម្បីឱ្យកូនម្ទេសដុះលូតលាស់ឫសបានឆាប់រហ័ស
- ត្រូវបញ្ចូលទឹកនៅតាមចន្លោះរងឱ្យពេញនៅពេលព្រឹក
- បើពិនិត្យនៅក្បែរគល់ម្ទេស ឃើញដីសើមខ្លាំងពេក គួរកាត់បន្ថយការបញ្ចូលទឹកតាមរង តែបើដីនោះស្ងួតរហូតពុំអាចលុញជាគ្រាប់ឃ្លីបាន យើងត្រូវប្រញាប់បញ្ចូលទឹកភ្លាម។

- ការខកខាងស្រោចទឹក ជាកត្តាមួយធ្វើឱ្យដើមក្រិន កាត់បន្ថយទិន្នផល ដូចជាជ្រុះផ្កា ផ្លែមិនភ្លឺរលោងជាដើម



បញ្ចូលទឹកតាមប្រលោះរង

- ជៀសវាងស្រោចទឹក ឬបញ្ចូលទឹកតាមរងនៅពេលល្ងាច វានាំឱ្យដីសើមនៅពេលយប់ជាញឹកញាប់នោះនិងបង្កជាបញ្ហារលួយឫស និងគល់ម្ទេស ហើយធ្វើឱ្យដើមងាប់។

### ៥. ៣. ការកាត់ស្លឹក ខ្នែងនិងដោតចំណារ

- ការអនុវត្តតាមបច្ចេកទេសកសិកម្មល្អ ដែលកសិករគួរអនុវត្តបន្ថែមទៀត នូវបច្ចេកទេសថែទាំដូចខាងក្រោម៖
- ត្រូវកាត់ស្លឹកផ្នែកខាងក្រោម (ជិតគល់)និងស្លឹកចាស់ៗចេញពីដើម
- កាត់ខ្នែងទើបនឹងដុះ នៅតាមដើមមេ រហូតដល់ខ្នែងចេញផ្កាថ្វាយព្រះ (ផ្កាក្រពុំ)
- បន្ទាប់ពីដាំបាន១០ទៅ១៥ថ្ងៃត្រូវដាក់ជន្ទល់តាមដើមនីមួយៗឬចងខ្សែក៏បាន។

វិធីនេះជួយឱ្យដើមស្រលះ មានខ្យល់ពន្លឺចេញចូលបានគ្រប់គ្រាន់ អាចកាត់បន្ថយជំងឺ និងសត្វល្អិតក្នុងចម្ការបានហើយ ដើមម្ទេសមិនងាយដួលក្នុងពេលប្រមូលផល។



បន្ទាប់ពីដាំហើយ ត្រូវចងកូនម្ទេស
នឹងបង្គោល ឬ ខ្សែទម្រ



ត្រូវកាត់ខ្នែងផ្នែកក្រោមផ្កាថ្ងាយ
ព្រះចេញ ឱ្យអស់

### ៥.៤. ការសម្អាតស្មៅ

ស្មៅជាជម្រកសត្វល្អិតចង្រៃ និងជំងឺរាតត្បាតដល់ដំណាំ។ ការទុកឬការយឺតយ៉ាវសម្អាតស្មៅក្នុងចម្ការម្ទេស និងងាយកើតជំងឺ សម្បុរសត្វល្អិតបំផ្លាញម្ទេស។ កត្តានេះហើយតម្រូវឱ្យកសិករប្រមូលផលម្ទេសបានតិចចំណាយថវិកាទិញថ្នាំពុលអស់ច្រើន។ ដូច្នេះយើងត្រូវសម្អាតស្មៅចេញតាមចន្លោះរង និងក្នុងចម្ការជាប្រចាំដើម្បីកម្ចាត់ជម្រកដែលបង្កបញ្ហាទាំងនេះចោល។

## ៦. ជំងឺ និងសត្វល្អិតចង្រៃ

### ៦.១. ជំងឺ

### ក. ជំងឺអង់ត្រាក់ណូស (Anthracnose)៖

ជាជំងឺផ្សិត បំផ្លាញផ្លែម្ទេស មានសញ្ញាជារង្វង់ច្រើនជុំ ហើយមានផ្សិតពណ៌ខ្មៅនៅពីលើរង្វង់ទាំងនោះ។ នៅដំណាក់កាល ជំងឺរាតត្បាតខ្លាំងវាធ្វើឱ្យម្ទេសរលួយ។





## វិធីការពារជំងឺអង់ត្រាកណូស (Anthracnose)

- ត្រូវដាំកូនម្ទេស ពីគុម្ពមួយ ទៅគុម្ពមួយ ឱ្យរង្វើល វាជួយឱ្យមានពន្លឺថ្ងៃ ខ្យល់ចេញចូលក្នុងចម្ការបានគ្រប់គ្រាន់ជួយឱ្យស្លឹក ផ្លែ ផ្កា រហ័សស្ងួត
- មិនគួរស្រោចទឹកពីលើដើមម្ទេសទេ និងជៀសវាងស្រោចទឹកពេលល្ងាច (ពពួកជំងឺផ្សិតចូលភាពសើមនៅពេលយប់)
- ប្រមូលកាកសំណល់បន្លែដែលប្រមូលផលហើយយកចេញពីចម្ការ
- បាញ់ថ្នាំកម្ចាត់ផ្សិតចន្លោះពី៥ទៅ១០ថ្ងៃម្តងដូចជាថ្នាំម៉ង់កូសែប (Mancozeb) ថ្នាំក្លរូថាឡូនីល (Chlorothalonil) ឬថ្នាំម៉ាណេប (Maneb)។ ថ្នាំនេះត្រូវបាញ់ឆ្លាស់គ្នាលាយជាមួយទឹកស្អិត ហើយបាញ់ពីក្រោម និងលើផ្ទៃស្លឹក និងផ្លែនៅពេលថ្ងៃល្ងាច។ ការបាញ់ថ្នាំផ្សិតទាំងនេះនៅមុនពេលកើតជំងឺ គឺថ្នាំទាំងនេះ វាបានជ្រាបចូលទៅក្នុងស្លឹក ដើម ហើយបានទប់ស្កាត់ស្ព័រជំងឺផ្សិតដែលទុំជាប់នឹងស្លឹក ឬដើមផ្លែ មិនអាចដុះលូតលាស់ជាជំងឺបាន។

## វិធីកម្ចាត់ជំងឺអង់ត្រាកណូស (Anthracnose)

- បេះផ្លែ ស្លឹក ដែលមានជំងឺប្រភេទនេះ ដាក់ក្នុងថង់យកទៅកប់ចោល។ បើទុកវាក្នុងចម្ការនោះស្ព័រជំងឺនេះ នឹងបាចសាចឆ្លងទៅកាន់ដើមម្ទេសផ្សេងៗកាន់តែខ្លាំង
- ត្រូវកាត់បន្ថយប្រើជីបំប៉ន និងស្រោចទឹកជោគខ្លាំងពេក
- ប្រើថ្នាំអាហ្សូហ្សីស្រូប៊ីន (Azoxystrobin) ឬកាប់តែន (Captan) លាយជាមួយទឹកស្អិតបាញ់ពីខាងលើ និងក្រោមស្លឹក នៅពេលល្ងាចដើម្បីទប់ស្កាត់ជំងឺនេះ។

### ខ. ជំងឺបាក់តេរីរីល ( Bacteria Wilt )

ជំងឺនេះធ្វើឱ្យស្វិតនៅផ្នែកខាងក្រោមដើម( ចំពោះកូនម្ទេសរោគសញ្ញាជំងឺនេះចាប់ផ្តើមស្រពោនពីខាងលើដើម ) ចាប់ផ្តើមស្រពោននៅពេលថ្ងៃ ហើយប្រែជាស្រស់នៅពេលយប់។

បាក់តេរី ដែលបង្កជំងឺនេះ រស់នៅក្នុងដីបានយ៉ាងយូរ ។ នៅពេលណាដីនៅជុំវិញដើមម្ទេសមានសំណើមខ្ពស់ហើយបរិយាកាសក៏មានសីតុណ្ហភាពខ្ពស់ផងដែរនោះជំងឺនេះនឹងចាប់ផ្តើមរាតត្បាតយ៉ាងឆាប់រហ័ស។

#### វិធីការពារ



- ជ្រើសរើសដីបណ្តុះកូនម្ទេសដែលគ្មានជំងឺប្រភេទនេះនិងប្រើពូជធន់ជាមួយនឹងជំងឺនេះ
- ដាំដំណាំឆ្លាស់គ្នា និង ជៀសវាងដាំដំណាំម្ទេសត្រប់ ឬប៉េងប៉ោះ បន្តលើដីតែមួយកន្លែង
- ថាសបណ្តុះ ឬកន្ទ្រងបណ្តុះកូនម្ទេសមិនត្រូវដាក់ជាប់ និងដី (អាចមានជំងឺប្រភេទនេះហូរពីដីកន្លែងផ្សេងមក )
- ប្រមូលកាកសំណល់ដំណាំ ដែលកើតជំងឺនេះ ទៅដុតចោលឱ្យឆ្ងាយពីចម្ការ
- រងដាំម្ទេសដែលកើតជំងឺស្រពោននេះ មិនត្រូវបង្ហូរទឹកចេញទៅរងផ្សេងទៀតទេ ពីព្រោះទឹកដែលហូរចេញ ពីរងនេះវាអាចនាំជំងឺឆ្លងទៅដំណាំនៅរងផ្សេងទៀតបាន។

## ៦. ២. សត្វល្អិតចង្រៃ

### ក. រុយស ( (White Fly)

រុយសជញ្ជក់រុក្ខរសស្លឹកម្ទេស មានជំងឺ រួចជំងឺនោះ បានចូលទៅក្នុងខ្លួនវា ហើយវាក៏បានផ្ទេរមេរោគ(វីរុស) ទៅដំណាំដែលវាបានជញ្ជក់ នាពេលបន្ទាប់នោះដែរ។ ការជញ្ជក់រុក្ខរសពីដើមមួយ ទៅដើមមួយធ្វើឱ្យជំងឺនេះ រាលដាលពាសពេញចម្ការ។



មេរុយសពេញវ័យ



រោគសញ្ញាដំណាំម្ទេសដែល មានជំងឺដោយសាររុយស

### វិធីការពារ

- គួរដាំប្រើគម្របប្លាស្ទិកគ្របដី
- កម្ចាត់ស្មៅ និងដំណាំជម្រករបស់រុយសចេញពីក្នុងចម្ការ
- ដាំម្ទេស ឱ្យរង្វើល ក្នុងចន្លោះពីដើមមួយទៅដើមមួយទៀត
- ស្រោចថ្នាំថ្យាមេថូហ្សាម (Thiamethoxam) និងកូនម្ទេសមុនពេលយកមកដាំ
- កប់ចោលកាកសំណល់ដំណាំនៅសល់បន្ទាប់ពីប្រមូលផលហើយ។

### វិធីកម្ចាត់

- ដកដើមដែលកើតជំងឺនេះយកកប់ចោល
- ជ្រើសរើសថ្នាំកម្ចាត់សត្វល្អិតណាមួយប្រើឆ្លាស់គ្នាលាយនិងទឹកស្អិតហើយបាញ់នៅពេលត្រជាក់ដូចជាៈ ថ្នាំថ្យាមេថូហ្សាម (Thiamethoxam) ថ្នាំអ៊ីមីដាក្លូរព្រីដ (Imidacloprid) ថ្នាំអាបាមិចទីន (Abamartin) ថ្នាំដាយណូតេហ្វូរ៉ាន់ (Dinotefuran) ថ្នាំអេម៉ាមិចទីន (Emamectine) ឬ ថ្នាំបុយប្រូហ្វេហ្សីន (Bupoofecine)។

## ៧. ការប្រមូលផល

- យើងអាចបេះផ្លែម្ទេសនៅពេលផ្លែចាស់ ឬក៏ផ្លែទុំអាស្រ័យទៅតាមតម្រូវការទីផ្សារ
- យើងគួរបេះផ្លែនៅពេលព្រឹកវាជួយរក្សារសជាតិ និងមានទម្ងន់ធ្ងន់
- ផ្លែដែលបានបេះត្រូវដាក់ក្នុងសម្ភារដែលមានផ្ទៃរលោង ដើម្បីជៀសវាងការកកិត និងជាំផ្លែ
- ជ្រើសរើសផ្លែម្ទេស ដែលល្អដាក់ដោយឡែក ពីផ្លែម្ទេសដែលមានជំងឺ ឬពីផ្លែមានសត្វល្អិតបំផ្លាញ
- ចង់ច្រកត្រូវមានរន្ធតូចៗដើម្បីមានខ្យល់ចេញចូលកុំឱ្យម្ទេសស្អោកឬទន់រលួយ។







ម្ទេសបានធ្វើចំណាត់ថ្នាក់ហើយ

## ឯកសារយោង:


១. សៀវភៅណែនាំបច្ចេកទេស ផលិតកម្មដំណាំបន្លែ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង East-West Seed International ខែធ្នូ ឆ្នាំ២០១៤

២. ឯកសារជំនួយសម្រាប់កសិករ ស្តីពីបច្ចេកទេសដាំដុះដំណាំបន្លែជាលក្ខណៈគ្រួសារ រៀបចំដោយអង្គការឃែរ (CARE) ប្រចាំស្រុកកំពង់ត្របែក. ២០១១

៣. សៀវភៅគោលការណ៍ណែនាំ អនុវត្តនៅចម្ការដំដឹសំខាន់ៗលើដំណាំបន្លែ រៀបចំដោយកម្មវិធីជាតិវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) អគ្គនាយកដ្ឋានកសិកម្ម ២០០៨

៤. ដំណាំបន្លែនៅកម្ពុជា នាយកដ្ឋានក្សេត្រសាស្ត្រ ១៩៩២